# ព្រះគុណូបការៈដ៏លើសលុបនៃសម្តេច ព្រះសង្ឃរាជថ្នាក់ទី ១ ចំពោះអក្ខរាវិរុទ្ធ

សម្តេចព្រះមហាសុមេធាធិបតី ជោតញ្ញាណោ **ជួន-ណាត** ព្រះសង្ឃរាជថ្នាក់ទី ១ នៃគណៈមហានិកាយ ព្រះអង្គមានព្រះទ័យស្រលាញ់អក្សរសាស្ត្រជាតិណាស់។ ព្រះអង្គទ្រង់មិនសំចៃព្រះកាយពលដើម្បីនឹងជួយរុញច្រានចលនាខេមរយានកម្ម តាំងពីអង្គការនេះកើតឡើង រហូតទល់ពេលចូលទិវង្គតនៃព្រះអង្គ។

ព្រះអង្គទ្រង់យកព្រះទ័យទុកដាក់ជានិច្ច ចំពោះចលនាខេមរយានកម្ម ចាប់តាំងពីថ្ងៃទី១២ កក្កដា គ.ស. ១៩៦៧ ដែលសហជីវិន វណ្ណ-មូលីវណ្ណ រដ្ឋមន្ត្រីក្រសួងអប់រំជាតិ និងសហការី បានចូលក្រាបបង្គំគាល់នៅមហាកុដិជាលើកដំបូងបង្អស់ ដើម្បីសុំព្រះអង្គទ្រង់គង់ជាអធិបតីនៃចលនាខេមរយានកម្ម។ ពេលនោះសម្តេចព្រះសង្ឃរាជទ្រង់បានទូន្មានថា "សុំឲ្យចាត់ការនេះឲ្យហ្មត់ចត់ កុំគិតងាយ ពីព្រោះកុំឲ្យខុសចំពោះការសរសេរពាក្យពេចន៍ខ្មែរ ដែលខុសឆ្គងយ៉ាងច្រើនកាលពីមុន ដូចជាការកត់ត្រាហៅឈ្មោះស្រុក ភូមិ ខេត្ត ឬការសរសេរឃើហោលើផ្ទះ ឬកញ្ចប់នំជាដើម។ កំហុសក្នុងការសរសេរពាក្យជាភាសាខ្មែរនេះមានខុសរហូតដល់ទៅ សរសេរបញ្ជីជាតិអត្រានុកូលដ្ឋានជាដើម" ។

សម្តេចព្រះសង្ឃរាជទ្រង់សព្វព្រះទ័យថា នឹងជួយពិនិត្យស្នាដៃផ្សេងៗដែលកើតពីចលនានេះឲ្យតែគណៈកម្មការ ឬអ្នកនិពន្ធ យកមកគាល់ថ្វាយព្រះអង្គផ្ទាល់ចុះ។

ព្រះរាជូបត្ថម្ភទាំងនេះសឲ្យឃើញថា សម្តេចទ្រង់ស្រលាញ់ភាសា និង

អក្សរសាស្ត្រជាតិណាស់ ទោះបីព្រះអង្គមានកិច្ចការមមាញឹកយ៉ាងណាក៏ដោយ ព្រះទ័យព្រះអង្គទ្រង់ជាប់ជំពាក់ជានិច្ច ចំពោះអង្គការយើង ដោយទ្រង់ប្រទានឱវាទផ្សេងៗ ឬក៏ណែនាំក្នុងកិច្ចការយ៉ាងណាដែលនាំឲ្យភាសាជាតិយើង ងើបមុខត្រដែតក្នុងផ្ទៃរាបអន្តរជាតិ។

គណៈកម្មាធិការជាតិ បានលើកព្រះអង្គជា ព្រះអគ្គមគ្គុទ្ទេសក៍ដ៏ឆ្នើមក្នុងការណែនាំប្រែពាក្យខ្មែរ ព្រះអង្គទ្រង់បានជួយបកប្រែពាក្យខ្មែរ តាំងពីកំណើតខេមរយានកម្មមកម្ល៉េះ គឺឆ្នាំទី ១ និងទី ២ មានចំនួន ១០.៦៣៩ ពាក្យហើយមកដល់ឆ្នាំទី ៣ មុនទិវង្គតកាលនៃព្រះអង្គបានចំនួន ៦៨៤ ពាក្យទៀត។ សូមបញ្ជាក់ថា ព្រះអង្គទ្រង់មានចំណេះវិជ្ជាខាងបាលីនិងសំស្ក្រឹតជ្រៅជ្រះណាស់ តែព្រះអង្គយកព្រះទ័យទុកដាក់ជាទីបំផុត ចំពោះពាក្យខ្មែរ មានសំនៀងខ្មែរពិតប្រាកដ។ ព្រះអង្គទ្រង់ឆ្លៀតពេលសម្រួលពាក្យបកប្រែ ហើយដោយឆ្នូលពាក្យជាឃ្លាប្រយោគ ឲ្យមកជាខ្មែរទាំងស្រុង មានលក្ខណៈវិទ្យាសាស្ត្រពេញលេញបានចំនួន ៤២០ ពាក្យនៅឆ្នាំទី ១ ។

ឧទាហរណ៍៖

ការខ្វះចម្វាញ់ ទៅជា កង្វះចម្វាញ់ - ការភ្ជាប់ ទៅជា បញ្ជាប់
ការឆេះ - ចំហេះ, ការវាយ - រង្វាយ, ការថែទាំ - តំហែទាំ
ការហុច - លំហុច, ការផ្ដើមគំនិត - បណ្ដើមគំនិត, ការលាត –ល្បាត
ការផ្ទៀងផ្ទាត់ - បន្ទៀងបន្ទាត់, ការអារ - អំណារ

ឧទាហរណ៍ទាំងអម្បាលម៉ានខាងលើនេះបញ្ជាក់ថា ព្រះអង្គសព្វព្រះរាជហឫទ័យយ៉ាងខ្លាំង ចំពោះពាក្យខ្មែរសុទ្ធ សមព្រះឋានៈជាអ្នកខ្មែរនិយមពេញទី។

ទោះទ្រង់រវល់នឹងភ្ញៀវ ឬទ្រង់ជាប់រវល់ក្នុងព្រះកិច្ចការយ៉ាងណាក៏ដោយ ព្រះអង្គទ្រង់ព្រះអនុញ្ញាតសមាជិកអង្គការយើង ឲ្យចូលក្រាបថ្វាយបង្គំ សូមព្រះរាជយោបល់បានគ្រប់ពេលមិនថាយប់ ឬថ្ងៃឡើយ។ ការចូលថ្វាយបង្គំ

គាល់ជាផ្លូវការ នៃអង្គការយើងមានចំនួន ២០០ ដងក្នុងកំឡុងពេលសិក្សា។

សម្ដេចព្រះសង្ឃរាជជាអម្ចាស់ ទ្រង់សព្វព្រះរាជហឫទ័យចំពោះអក្សរជាតិណាស់ ដោយព្រះអង្គបានគាំទ្រជាទីបំផុតចំពោះអង្គការខេមរយានកម្មសិក្សា ក្រៅពីព្រះរាជយោបល់និងបកប្រែពាក្យខ្មែរ ព្រះអង្គទ្រង់ផ្ដល់អត្ថបទជាច្រើនមកពីអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃខេមរយានកម្ម ដើម្បីលើកស្ទួយភាសាជាតិ និងទស្សនាវដ្ដីខេមរយានកម្មឲ្យមានពន្លឺត្រចះត្រចង់គ្រប់ពេលវេលា។ ព្រះរាជអត្ថបទទាំងនោះមានដូចតទៅ៖

- ទស្សនៈនៃសម្ដេចព្រះសង្ឃរាជ ចុះក្នុងទស្សនាវដ្ដីឆ្នាំទី ២ លេខ ១
- កំណាព្យ ៖ ការសេពគប់ ........................ លេខ ៤
- កំណាព្យ ៖ រំលឹកអក្សរខ្មែរ ...................... លេខ ៧
- កំណាព្យ ៖ កតញ្ញូតាភាវៈនៃអ្នកដឹកគុណ ចុះផ្សាយក្នុងទស្សនាវដ្ដីឆ្នាំទី ៣ លេខ ១

ព្រះរាជូបត្ថម្ភទាំងនេះ ទោះបីព្រះអង្គយាងចូលទិវង្គតទៅហើយក៏ដោយ អង្គការយើងនៅតែលើកយកព្រះរាជោវាទទាំងនោះ ទុកជាគតិធម៌ជានិច្ចចំពោះកិច្ចការនៃខេមរយានកម្ម។

គណៈកម្មាធិការជាតិ

**ខេមរយានកម្ម**

X X X